ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 10 / 2012
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/127

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ០១ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១១៤

រៀបចំដោយ: ដាវ អានសាន និង Roger Phillips

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក ឌុច ផារី, លោក Roger Phillips |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោកស្រី Beini YE, លោក វ៉ែន ពៅ, លោកស្រី Christine MARTINEAU, លោក ផង់ វិចិត្រ |
| សាក្សី៖ លោក ខៀវ អេន (TCW-320) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុធាវី |
| ផ្សេងៗ៖ លោក Jay GALIK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖១៥.១០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៣៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ | មេធាវីការពារក្ដី អៀង សារី | ០៩.០៧ | ០៩.០៩ |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ | មេធាវីការពារក្ដី នួន ជា | ១២.០២ | ១២.០៣ |
| ការតាំងសំណួរទៅសាក្សី ខៀវ អេន (TCW-320) | អង្គជំនុំជម្រះ | ០៩.១០ | ០៩.១៨ |
| | សហព្រះរាជអាជ្ញា | ០៩.១៩ | ១១.៥១ |
| | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី | ១១.៥២ | ១៥.២៣ |
| | ចៅក្រម Lavergne | ១៥.២៣ | ១៥.៣៣ |
| | មេធាវីការពារក្ដី នួន ជា | ១៥.៣៣ | ១៥.៥៩ |
| ការប្រកាសអំពីការដាក់សំណើផ្ទាល់មាត់ | អង្គជំនុំជម្រះ | ១៦.០០ | ១៦.០៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការ</u>**

ជនជាប់ចោទ អៀង សារី (ឯកសារ E229) និង នួនជា តាមរយៈមេធាវីរបស់គាត់ (ម៉ោង ១២.00) បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការដោយផ្ទាល់ ដោយសារជនជាប់ចោទមានបញ្ហាសុខភាព។ អង្គជំនុំជម្រះបានសម្រេចតាមការស្នើសុំរបស់ជនជាប់ចោទ។

**<u>ការតាំងសំណួរទៅសាក្សី ខៀវ អេន (TCW-320)</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋម និងសំណួរបញ្ជាក់មួយចំនួន ដែលទាក់ទងនឹងប្រវត្តិសាវតា សក្ខីកម្មរបស់សាក្សី និងបានប្រាប់អំពីសិទ្ធិនិងករណីកិច្ចដល់សាក្សី បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី ដដែលនេះ។ ជាបន្តបន្ទាប់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅកាន់សាក្សី។

**<u>ការប្រកាសអំពីការដាក់សំណើផ្ទាល់មាត់</u>**

ដោយផ្អែកលើស្ថានភាពដែលជនជាប់ចោទ អៀង សារី បន្តស្ថិតនៅក្នុងមន្ទីរពេទ្យនោះ និងត្រូវបានតាមដានពិនិត្យស្ថានភាពសុខភាពរបស់គាត់ជាបន្ត អង្គជំនុំជម្រះមានបំណងឲ្យមានការពិភាក្សាជាមួយភាគីពាក់ព័ន្ធតាមការលើកឡើងជាសេចក្តីស្នើដោយផ្ទាល់មាត់នៅក្នុងសវនាការ ទៅលើបញ្ហាកំណត់កាលបរិច្ឆេទចូលរួមរបស់សាក្សីនានា ពាក់ព័ន្ធនឹងបញ្ហាកើតឡើងពីអវត្តមានរបស់ អៀង សារី ក្នុងសវនាការ។ ការពិភាក្សានេះនឹងត្រូវបន្តពីការស្តាប់សក្ខីកម្មរបស់សាក្សី TCW-320។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចដំណើរការនីតិវិធី ផ្ទៃក្នុង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/438 | D279/4 | 00373429-00373438<br>00375870-00375877<br>00426427-00426435 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ អេន KHIEV Ēn<br>Written Record of Interview of KHIEV Ēn ខៀវ អេន<br>Procès verbal d'audition de témoin KHIEV Ēn ខៀវ អេន | P | 00373430-31, 00373433, 00373436, 00373435 | 00375871-72, 00375873-74, 00375875, 00375876 | 00426428-29, 00426430-31, 00426433, 00426432 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/231 | 13.7 | 00017124-00017127 00528385-00528387, 00183360-00183362 00323930-00323931 | កំណត់អង្គប្រជុំការងារឃោសនាការ ថ្ងៃ ៨ មិនា ១៩៧៦<br>Minutes of meeting on information affairs on 8/3/76<br>Minutes of meeting on information affairs on 8/3/76 | P | 00017126-27 | 00183362 | 00323931 |
| E3/1550 | 5.30 | 00006658-00006711, 00008921-00009001, 00003117-00003122 00831472-00831473, 00819912-00819920, 00759691-00759696, 00249844-00249845, 00182805-00182808 00766901-00766910, 00296021-00296021, 00766888-00766891, 00766791-00766793 | ចម្លើយ ហ៊ូ នឹម ហៅភាស់ ក្រសួងឃោសនាការ អំពីប្រវត្តិបក្ស សេអ៊ីអា<br>[Partial T.] Confession of Hou Nim alias Phoas<br>[Partial T.] Aveux de HU Nim alias Phoas à S-21 | P | 00003118, 00006662 | 00242945, 00249844 | 00766888, 00766902 |
| E3/1744 | 16.109 | 00039900-00039907 00746751-00746763 00710256-00710270 | ឈ្មោះអ្នកទោសដែលបានសួរចម្លើយនៅថ្ងៃទី ១៨ មេសា ១៩៧៨<br>Name of the prisoners have interrogated on 18/4/78<br>Noms des prisonniers interrogés le 18 avril 1978 | P | 00039907 | 00746762 | 00710269 |
| E3/342 | D288/6.68.1 | 00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១ | P | 00329840 | 00329840 | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចបន្តដំណើរការសវនាការ ដោយអវត្តមានជនជាប់ចោទអៀងសារី តាមការស្នើសុំរបស់ជនជាប់ចោទ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទមានលេខឯកសារ E229) និងសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជា

ឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី ខៀវ អេន ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកដល់សវនាការវិញ នៅមុនម៉ោង ០៩.០០ព្រឹក នៃថ្ងៃបន្ទាប់។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ០២ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២

| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
| --- | --- |
| (signature) | (signature) |
| **ដាវ អានសាន** | **Roger Phillips** |